# ការសំភាសន៍របស់ម៉ាក់យាយ អៀម ខេម

កៈ អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍អៀម ខេម

## <u>ការសង្ខេបប្រវត្តិរបស់ម៉ាក់យាយ អៀម ខេម</u>

ម៉ាក់យាយ អៀម ខេម មាន ម៉ាក់យាយ អៀម ខេម មានភេទស្រី ម៉ាក់យាយ អៀម ខេម មានទីលំនៅបច្ចុប្បន្ននៅភូមិ៕

កៈ
ចឹងជាដំបូងខ្ញុំសូមអរគុណាច្រើនម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍
នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ
នឹងប្រវត្តិរបស់ដូចតា ដូចម៉ាក់យាយចឹងអោយកូនចៅរបស់ម៉ាក់ស្គាល់ពីប្រវត្តិម៉ាក់យាយ
នឹងឪពុកម្ដាយរបស់ម៉ាក់យាយ
ចឹងពេលដែរខ្ញុំសំភាសន៍ម៉ាក់យាយហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu
ចឹងហាសម៉ាក់យាយ
ចឹងតើម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ទាក់ទងពីប្រវត្តិរបស់ម៉ាក់យាយ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេម៉ាក់យាយ?

ខៈ និយាយពីប្រវត្តិរបស់ខ្ញុំនឹងកំសត់ណាស់។

កៈ បាទចឹងម៉ាក់យាយចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី23 ខែ2 ឆ្នាំ2018 សំភាសន៍នៅភូមិអីគេម៉ាក់យាយ?

ខៈ ភូមិត្រគៀត។

កៈ នៅភូមិត្រគៀត ឃុំត្រពាំងគង ស្រុកអីគេដែរម៉ាក់យាយ?

ខៈ នៅស្រុកសំពោងទង។

កៈ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺបាទម៉ាក់យាយ ចឹងសំរាប់ឈ្មោះពេញរបស់ម៉ាក់យាយមានឈ្មោះអី គេដែរម៉ាក់យាយ?

ខៈ ខ្ញុំឈ្មោះអៀម ខេម។

កៈ ចុះមានឈ្មោះហៅក្រៅទេម៉ាក់យាយ?

ខៈ អត់មានទេ។

កៈ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះម៉ាក់យាយអីផ្សេងទេម៉ាក់យាយ?

ខៈ អត់មានទេ។

កៈ ចុះម៉ាក់យាយសព្វថ្ងៃនឹងម៉ាក់យាយអាយុប៉ុន្មានដែរម៉ាក់យាយ?

ខៈ ខ្ញុំអាយុ68ឆ្នាំហើយនឹង។

កៈ អាយុ68ឆ្នាំ ចុះម៉ាក់យាយមានចងចាំថាម៉ាក់យាយកើតនៅថ្ងៃខែឆ្នាំណាម៉ាក់យាយមានចងចាំទេ?

ខៈ អត់ចាំទេចេះតែមើលអត្តសញ្ញាណប័ណតានឹងទៅ។

កៈ បាទម៉ាក់យាយបាទ?

ខៈ មើលអត្តសញ្ញាណប័ណទៅឆ្នាំកំណើតនឹង។

កៈ ចុះខែនឹងក៏ម៉ាក់យាយអត់ចងចាំដែរណម៉ាក់យាយ?

ខៈ បើខែនឹងនៅខែអាសាឍ។

កៈ នៅខែអាសាឍ ចុះនៅខែបារាំងវិញម៉ាក់យាយមានដឹងថាខែអីគេវិញម៉ាក់យាយ?

ខៈ ខ្ញុំអត់ដឹងទេនឹង។

កៈ ចឹងសំរាប់ម៉ាក់យាយកើតនៅឆ្នាំ1950ម៉ាក់យាយ?

ខៈ ចាំ!ខ្ញុំដឹងប៉ុន្តែខ្ញុំអត់ចងចាំកន្ទុយនឹង។

កៈ បាទចុះម៉ាក់យាយបើឆ្នាំច័ន្ទគតិនឹងលក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាសម៉ាក់យាយឆ្នាំអីគេដែរ ម៉ាក់យាយ?

ខ៖ ខ្ញុំអត់ដឹងផងនឹង។

ក៖ ចឹងអត់ដឹងទេណាម៉ាក់យាយ ចុះសំរាប់ម៉ាក់យាយកើតនៅណាដែរម៉ាក់យាយ?

ខ៖ ខ្ញុំនៅកាលពីមុននឹងខ្ញុំនៅភូមិស្នោល ឃុំត្រពាំង អូនៅឃុំវល្លិ៍សរ ប៉ុន្តែឥឡូវនឹងខ្ញុំមកនៅភូមិត្រពាំងគោក។

ក៖ ប៉ុន្តែម៉ាក់យាយកើតនឹងម៉ាក់យាយកើតនៅណាដែរម៉ាក់យាយ?

ខ៖ បើកើតនៅភូមិកំណើតភូមិស្នោល ឃុំវល្លិ៍សរទេពីមុននឹងកាលពីកំណើតនឹង។

ក៖ បាទនៅឃុំអីគេដែរម៉ាក់យាយ?

ខ៖ នៅឃុំវល្លិ៍សរ នៅណោះ។

ក៖ ចុះភូមិនឹងភូមិអីគេដែរម៉ាក់យាយ?

ខ៖ នៅភូមិស្នោល។

ក៖ នៅភូមិស្នោល ស្រុកសំរោងទងដដែរនឹង ខេត្តកំពង់ស្ពឺនឹង
អូបាទម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មាន នាក់ដែរម៉ាក់យាយ?

ខ៖ ខ្ញុំមានបងប្អូននៅ4នាក់នឹង។

ក៖ ចុះមានស្រីប៉ុន្មាននាក់ដែរ ហើយប្រុសប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖ មានស្រី3នាក់ នឹងប្រុសម្នាក់នឹង។

ក៖ ចុះម៉ាក់យាយជាកូនទីប៉ុន្មានដែរម៉ាក់យាយ?

ខ៖ ខ្ញុំជាកូនទី1នឹង។

ក៖ អូ៎!ចឹងប្អូនៗៗរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយមានចងចាំទេ?

ខ៖ ចងចាំប្អូនបន្ទាប់ខ្ញុំនឹងឈ្មោះឡេ។

ក៖ ចុះប្រាប់មកទៀតម៉ាក់យាយ?

ខ៖ មួយទៀតប្អូនប្រុសនឹងឈ្មោះ ខុត។

កៈ ចុះប្អូនពៅម៉ាក់យាយ?

ខៈ ប្អូនពៅឈ្មោះរេប។

កៈ
ចុះម៉ាក់យាយមានចងចាំអនុស្សាវរីយ៍អីកាលពីម៉ាក់យាយនៅក្មេងៗជាមួយពួកគាត់ដែរទេ ធ្លាប់លេងឡឹកបាយឡ លេងបិទពួន ទៅស្រែ លេងមឹក លេងអីចឹងហាសម៉ាក់យាយ?

ខៈ អត់បាននៅផ្ទះលេងទេខ្ញុំទៅតែស្រែមើលគោអីចឹងទៅ។

កៈ ជាមួយបងប្អូនរបស់ម៉ាក់យាយ?

ខៈ ចា៎!ប្អូនមីតូចក្រោយខ្ញុំនឹងវាធំជាងគេវាធ្វើការខ្ញុំដឹងតែទៅស្រែ
ព្រលឹមឡើងទៅស្រែមើលគោចឹងទៅ អត់បានលេងនៅផ្ទះទេ។

កៈ អូ៎!បាទម៉ាក់យាយ?

ខៈ ខ្ញុំកំសត់ណាស់។

កៈ ចុះកាលពីនៅក្មេងៗនឹងម៉ាក់យាយចូលចិត្តលេងអីគេជាមួយបងប្អូនដែរម៉ាក់យាយ?

ខៈ អត់សូវបានលេងអីជាមួយបងប្អូនទេ។

កៈ ប៉ុន្តែម៉ាក់យាយចូលចិត្តធ្វើអីជាមួយបងប្អូនដែរម៉ាក់យាយ?

ខៈ ខ្ញុំព្រលឹមទៅហើយអត់បាននៅលេងនៅផ្ទះទេចេញ។

កៈ ម៉ាក់យាយចេញទៅម្នាក់ឯងរឺក៏ទៅជាក្រុមគ្រួសារដែរម៉ាក់យាយ?

ខៈ ចេញទៅស្រែចឹងទៅទៅមើលគោចឹងទៅ។

កៈ ទៅជាមួយនរណាគេដែរម៉ាក់យាយ?

ខៈ ទៅជាមួយបងប្អូនជីដូនមួយនឹង។

កៈ អូ៎!ភាគច្រើននឹងយើងទៅមើលគោនឹងទៅមួយថ្ងៃទល់ល្ងាចរឺយ៉ាងម៉េចដែរម៉ាក់យាយ?

ខៈ ចា៎!បាយហើយថ្ងៃត្រង់នឹងល្ងាចមកវិញ។

កៈ យើងវេចបាយទៅណាម៉ាក់យាយ?

ខ៖ អត់វេចទេ។

ក៖ មានប្អូនៗៗនឹងយកបាយទៅអោយដែរ?

ខ៖ អត់ទេមកញាំបាយដោយខ្លួនឯងនឹងមកបាយនៅផ្ទះវិញនឹងហូបហើយចេញទៅមកហូបបាយផ្ទះ វិញល្ងាចនឹង។

ក៖ អូ៎!បាទចឹងមានន័យថាពេលនឹងយើងដឹកគោមកផ្ទះវិញហើយនឹង។

ខ៖ ចា៎!ដឹកគោមកវិញនឹង។

ក៖ ដឹកគោមកដល់ពេលថ្ងៃបានដឹកគោទៅវិញទៀតនឹង?

ខ៖ ចា៎!នឹងហើយ។

ក៖ ចឹងមួយថ្ងៃនឹងយើងដឹកពីរដើងហើយណាមីង?

ខ៖ ចា៎!ថ្ងៃត្រង់នឹងបានទៅឃ្វាលតែម្ដងនឹងទេ។

ក៖ បាទម៉ាក់យាយចុះប្អូនៗៗរបស់ម៉ាក់យាយនឹងគាត់ធ្វើអីគេដែរឥឡូវនឹងម៉ាក់យាយ?

ខ៖ ប្អូននោះវាកំសត់ដែរនឹងវាធ្វើពុសអូសនោះ។

ក៖ អូ៎!គាត់ពុសអូស។

ខ៖ ពុសអូសនឹងធ្វើជាកម្មករគេដែរនឹងហាស។

ក៖ ចុះប្អូនផ្សេងទៀតនៅណាធ្វើអីផ្សេងទៀតទៅម៉ាក់យាយ?

ខ៖ ប្អូនផ្សេងទៀតនឹងនៅវត្តចំបក។

ក៖ និយាយទៅពួកគាត់នៅវត្តចំបកទាំងអស់ហោសម៉ាក់យាយ?

ខ៖ មើលអ្នកទីមួយនឹងនៅវត្តចំបក
បន្ទាប់មកនៅវត្តចំបកបន្ទាប់នឹងទី3នឹងនៅជើងផ្សារស្ដីនោះនឹង។

ក៖ បាទម៉ាក់យាយបាទ?

ខ៖ ហើយ៣គេនៅនឹងឯង។

កៈ ចឹងម៉ាក់យាយក៏នៅនឹងដែរ?

ខៈ ចាំ!នៅនឹងដែរ។

កៈ និយាយចឹងបងប្អូនរបស់ម៉ាក់យាយទាំងអស់នឹងគឺនៅខេត្តកំពង់ស្ពឺទាំងអស់គ្នានឹង?

ខៈ ចាំ!!!នៅនឹង។

កៈ អូ្ន!បាទ ចុះម្តាយរបស់ម៉ាក់យាយនឹងមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ គាត់ឈ្មោះយាយយ៉ា។

កៈ ចុះដល់ឥឡូវនឹងម៉ាក់យាយអត់ដឹងថាគាត់អាយុប៉ុន្មានទេណាម៉ាក់យាយ?

ខៈ អត់បានគិតផងនឹងគាត់ស្លាប់បាត់ហើយនឹង។

កៈ អូ្ន!ចុះម្តាយរបស់ម៉ាក់យាយនឹងគាត់កើតនៅណាដែរម៉ាក់យាយ?

ខៈ គាត់កើតនៅនឹងដែរនឹងនៅភូមិស្មោល នៅឃុំវល្លិ៍សរនឹងដែរនឹងហាស។

កៈ អូ្ន!ចុះឪពុករបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ គាត់មានឈ្មោះអៀម អ៊ុន។

កៈ ចុះគាត់កើតនៅណាដែរ?

ខៈ គាត់នៅនឹងនៅភូមិត្រគៀតនឹង។

កៈ ចុះឪពុករបស់ម៉ាក់យាយនឹងគាត់ស្លាប់បាត់ហើយនឹងមែនទេម៉ាក់យាយ?

ខៈ គាត់ស្លាប់បាត់ហើយនឹងឪពុករបស់ខ្ញុំនឹងគាត់ស្លាប់បាត់ហើយនឹង។

កៈ ចុះកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខៈ គាត់ធ្វើស្រែនឹងឡើងត្នោត។

កៈ អូ្ន!ភាគច្រើននឹងអ្នកនៅភូមិនឹងសុទ្ធតែឡើងត្នោតណាម៉ាក់យាយ?

ខៈ ចាំ!ឡើងត្នោតនឹង។

កៈ ដោយសារតែមានដើមត្នោតច្រើននឹង?

ខ៖ មានដើមត្នោតច្រើននឹង។

ក៖ ចុះកាត់ជាមនុស្សកាចរឺមួយក៏ស្លូតដែរម៉ាក់យាយ?

ខ៖ គាត់មិនកាចមិនស្លូតទេធម្មតានឹង។

ក៖ នឹងឪពុករបស់ម៉ាក់យាយ?

ខ៖ ចាំ!ហើយខ្ញុំនៅតូចខ្ញុំធ្វើស្រែចឹងទៅ គាត់ទៅធាក់ស៊ីខ្លូចឹងទៅ។

ក៖ អូ៎!គាត់ទៅធ្វើការដល់ភ្នំពេញហោសម៉ាក់យាយ?

ខ៖ ចាំ!គាត់ធាក់ស៊ីខ្លូនឹង។

ក៖ រហូតទាល់តែពេលណាដែរ?

ខ៖ រហូតទាល់តែគាត់ចាស់នឹង។

ក៖ គាត់ទៅវិលល្ងាចរឺយ៉ាងម៉េចដែរម៉ាក់យាយ?

ខ៖ គាត់ទៅចឹងទៅមួយអាទិត្យនឹងគាត់មកម្តងនឹងចាំនឹងហើយ។

ក៖ អូ៎!ហើយគាត់ធាក់ស៊ីខ្លូមកវិញចឹងទៅ?

ខ៖ ចាំ!មួយអាទិត្យមកម្តងនឹង។

ក៖ អូ៎!ចុះម្តាយរបស់ម៉ាក់យាយនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខ៖ គាត់ធ្វើស្រែដែរនឹង។

ក៖ ចុះគាត់ជាមនុស្សបែបណាដែរម៉ាក់យាយកាច រឺមួយក៏ស្លូតដែរម៉ាក់យាយ?

ខ៖ គាត់មិនកាច មិនស្លូតនឹងវាល្មមនឹងកណ្តាល។

ក៖
ចុះកាលពីម៉ាក់យាយនៅជាមួយពួកគាត់មានយាយធ្លាប់ចងចាំអនុស្សាវរីយ៍អីជាមួយពួកគាត់ទេ ជាមួយឪពុកម្តាយរបស់ម៉ាក់យាយហាស?

ខ៖ អត់មានទេមានធ្វើតែស្រែនឹងឃ្វាលគោអីតែប៉ុណ្ណឹងទេអត់មានអីប្លែកទេ។

កៈ អូ!ធ្វើស្រែនឹងឃ្វាលគោជាមួយពួកគាត់នឹង?

ខៈ ចាំ!ធ្វើចឹង។

កៈ ចុះនៅផ្ទះម៉ាក់យាយធ្លាប់ធ្វើអីគេដែរជាមួយពួកគាត់អត់
ដូចថាដាំបាយធ្វើម្ហូបអីចឹងទៅ?

ខៈ បានដាំបាយអីប៉ុណ្ណឹង ធ្វើម្ហូបអីប៉ុណ្ណឹង។

កៈ ហើយនឹងយើងញាំបាយអីជាមួយគ្នាទៅណាម៉ាក់យាយ?

ខៈ ចាំៗៗៗ!!នឹងហើយ។

កៈ អូ!បាទ
ចុះម្ដាយរបស់ម៉ាក់យាយនឹងគាត់ធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីនៅក្មេងទៅម៉ាក់យាយដែរទេ?

ខៈ គាត់អត់ដែរប្រាប់ផងនឹង។

កៈ ចុះឪពុករបស់ម៉ាក់យាយវិញ?

ខៈ ឪពុកនឹងក៏អត់ប្រាប់ដែរ។

កៈ ចុះចឹងយាយតាខាងឪពុកនឹងម៉ាក់យាយមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ យាយតាខាងឪពុកនឹងស្គាល់ ឪពុកខាងឪពុកជីតារបស់ខ្ញុំនឹងឈ្មោះតាអៀម។

កៈ ចុះយាយវិញ?

ខៈ យាយនឹងឈ្មោះយាយលាប់។

កៈ គាត់ឈ្មោះយាយលាប់ ចុះយាយតាខាងម្ដាយវិញ?

ខៈ យាយតាខាងម្ដាយឪពុករបស់គាត់នឹងឈ្មោះតាកាន់
ហើយម្ដាយរបស់គាត់ឈ្មោះយាយគង់ ។

កៈ ប៉ុន្តែទាំងតា ទាំងយាយគាត់កើតនៅណាដែរម៉ាក់យាយមានដឹងអត់?

ខៈ បើតាមខ្ញុំដឹងនឹងគាត់នៅភូមិស្មោលដែរ នៅឃុំវល្លិ៍សរដែរនឹង។

កៈ ចា៎!ម៉ាក់យាយទាំងអស់គ្នាតែម្ដងនឹងហោសម៉ាក់យាយ?

ខៈ ចា៎!!នឹងហើយ។

កៈ ចុះម៉ាក់យាយនៅនឹងយូរនៅម៉ាក់យាយ ស្នាក់នៅនឹងយូរនៅម៉ាក់យាយ?

ខៈ ខ្ញុំរស់នៅយូរហើយ។

កៈ ប្រហែលជាប៉ុន្មានឆ្នាំហើយម៉ាក់យាយ?

ខៈ មើលយើងតាំងពីមុនជំនាន់លុនណុលនឹងមក
ជំនាន់លុនណុលនឹងមកខ្ញុំមកនៅនឹងហាស នៅនឹង
ហើយចុះពីអាពតនឹងមកនៅនឹងរហូតទៀតនឹង។

កៈ និយាយចឹងចូលចង់និយាយទៅម៉ាក់យាយនៅនឹងរហូតនឹង?

ខៈ ចា៎!!នឹងហើយនៅនឹង។

កៈ ចុះម៉ាក់យាយមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេម៉ាក់យាយ?

ខៈ អត់មានផងនឹង។

កៈ អត់មានទេនៅវៀតណាម នៅថៃអីក៏អត់មានដែរណាម៉ាក់យាយ?

ខៈ អត់មានទេ។

កៈ ចុះស្វាមីរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ គាត់មានឈ្មោះគឹម មួន។

កៈ ចុះម៉ាក់យាយមានចងចាំថាម៉ាក់យាយរៀបការជាមួយតានៅថ្ងៃខែឆ្នាំណាដែរទេ?

ខៈ អត់ទេស្គាល់តែឆ្នាំខ្មែរនឹងមិនសូវចាំទេគ្រាន់តែថាការ បើការនៅខែផ្គុន
មិនបានយកចិត្តទុកដាក់ទេ ណាស់។

កៈ បាទម៉ាក់យាយបាទនឹង?

ខៈ ខែផ្គុននឹងទាំងពីខ្ញុំអាយុ18ឆ្នាំណោះ អាយុ18ឆ្នាំឥឡូវនឹងអាយុ68ឆ្នាំហើយគិតមើល។

កៈ អាយុ18ឆ្នាំឥឡូវនឹងអាយុ68ឆ្នាំចឹងមានន័យថាការអស់50ឆ្នាំហើយនឹង?

ខ៖  ការអស់50ឆ្នាំហើយនឹង អាយុ18ឆ្នាំឥឡូវនឹងអាយុ68ឆ្នាំវាអស់50ឆ្នាំហើយនឹង។

ក៖  អស់50ឆ្នាំហើយនឹង
ចុះនៅពេលដែរម៉ាក់យាយសំរេចចិត្តរៀបអាពាហ៍ពិពាហ៍នឹងរឺក៏ឪពុកម្ដាយ
ជាអ្នកសំរេចចិត្តរៀបអោយដែរម៉ាក់យាយ?

ខ៖  គាត់ម៉ែឪទុកដាក់នឹង។

ក៖  ចឹងឪពុកម្ដាយជាអ្នករៀបចំអោយហោសម៉ាក់យាយ?

ខ៖  ចា៎!ខ្ញុំតាមគាត់នឹង។

ក៖  អូ៎!បាទចុះនៅពេលដែរតាចូលស្ដីដណ្ដឹមម៉ាក់យាយនឹងមានជាជំនូនទេម៉ាក់យាយ?

ខ៖  ជាជំនូនហោស?

ក៖  ជាថ្លៃទឹកដើហាសម៉ាក់យាយ?

ខ៖  មានជាជំនូនធម្មតានឹងផ្លែឈើអីនឹងដូចជាចេកអីនឹង។

ក៖  ប៉ុន្តែកាលណុងគេមិនជូនជាលុយអីទេណាម៉ាក់យាយ?

ខ៖  អត់មានទេមានជាផ្លែឈើនឹង។

ក៖  អូ៎!បាទម៉ាក់យាយនឹង?

ខ៖  មានជាផ្លែឈើនឹងទេ។

ក៖  អូ៎!បាទ ចុះពេលដែរម៉ាក់យាយការនឹងដាច់ពលពតហើយនៅ?

ខ៖  ការតាំងពីជំនាន់។

ក៖  មុនពលពតរឺមួយក៏ដាច់ពលពតដែរម៉ាក់យាយ?

ខ៖
ការតាំងពីសម្ដេចមិនទាន់រដ្ឋប្រហារណោះមុននោះយូរដែរហើយនឹងអស់50ឆ្នាំហើយនឹង។

ក៖  អូ៎!បាទម៉ាក់យាយនឹង?

ខ៖  តាំងបីសម្ដេចមិនទាន់រដ្ឋប្រហារហោស តាំងពីនៅសង្គមរាស្ត្រនិយមមកនឹងហើយ។

កៈ ចុះហេតុអីបាន ខ្ញុំអាចសុំសួរម៉ាក់យាយតិចថាហេតុអីបានជាតាស្រលាញ់ម៉ាក់យាយ ហើយស្រលាញ់នៅពេលណាដែរបានតាចូលស្ដីដណ្ដឹងម៉ាក់យាយដែរចឹងហាស?

ខៈ គាត់គិតថាចាស់ៗៗដែរនឹង។

កៈ អូ៎!និយាយចឹងមានន័យថាម៉ាក់យាយអត់ស្គាល់តាទេពីមុននឹង?

ខៈ ចា៎!ខ្ញុំអត់ស្គាល់គាត់ ហើយគាត់អត់ស្គាល់ខ្ញុំប៉ុន្តែចាស់ៗៗគាត់អ្នកដឹកនាំនឹង។

កៈ អូ៎!បាទចឹងមានន័យថាសំរេចខាងចាស់ៗៗគាត់អ្នកអូខេជាមួយយើងមែនទេ?

ខៈ ចា៎!!!!នឹងហើយ។

កៈ ចុះម៉ាក់យាយពេលណុងម៉ាក់យាយធ្លាប់បានចូលរៀនទេម៉ាក់យាយ?

ខៈ ខ្ញុំអត់សូវបានរៀនទេម៉ែអោយនៅមើលប្អូន
បងអត់មើលប្អូនហើយខ្ញុំបានរៀនអកៈរៈកម្មហើយទេនឹង
ហើយធំណាស់ហើយបានរៀនអកៈរៈកម្មនឹងរៀនបានថ្នាក់ទី2នឹង។

កៈ បាទចុះគិតថាម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរទេម៉ាក់យាយ?

ខៈ អត់ទេអត់ចេះអីទេនឹង។

កៈ អូ៎ៗ!ចឹងហោស?

ខៈ មានតែរៀនខ្មែរថ្នាក់ទី2នឹងរៀនអកៈរៈកម្មនឹង។

កៈ ប៉ុន្តែរៀននឹងរៀននៅណាដែរម៉ាក់យាយ?

ខៈ រៀននៅភូមិនឹងដែររៀននៅភូមិស្រុកកំណើតនឹង។

កៈ ចុះម៉ាក់យាយមានបងប្អូន រឺក៏មិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាដែរទេម៉ាក់យាយ?

ខៈ មានតែគ្នាអ្នកស្រុកនឹង ។

កៈ ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរខ្លះទៅម៉ាក់យាយ?

ខៈ មានតែអ្នកស្រុកនឹងខ្ញុំអត់ចាំគេដែរនឹង។

កៈ ប៉ុន្តែម៉ាក់យាយមានចងចាំថាម៉ាក់យាយធ្លាប់បានធ្វើអីគេខ្លះដែរជាមួយពួកគាត់ដែរទេ?

ខ៖ អត់មានធ្វើអីទេមានតែបណ្តើរគ្នាទៅរៀននឹងតាមធម្មតានឹង។

ក៖ អូ៎!ដូចថា?

ខ៖ ឈ្លោះគ្នាក៏អត់ដែរ។

ក៖ ធ្លាប់ទៅស្រែរឺមួយក៏ធ្លាប់លេងអីជាមួយគ្នាចឹងហាសណាស់ម៉ាក់យាយ?

ខ៖ ចាំ!ធ្លាប់ទៅឃ្វាលគោអីជាមួយគ្នានឹង ហើយធ្វើអីជាមួយគ្នាចឹង។

ក៖ បាទហើយធ្លាប់លេងអីៗជាមួយគ្នាចឹង?

ខ៖ ចាំ!ក្មេងស្រីដុចគ្នានឹងទេលេងនឹងឃ្វាលគោអីនឹង។

ក៖ បាទម៉ាក់យាយចុះម៉ាក់យាយធ្លាប់ធ្វើការងារអីគេខ្លះដែរ
តាំងពីក្មេងនឹងរហូតមកដល់ពេលនេះហាស?

ខ៖ អត់មានធ្វើការអីទេធ្វើតែស្រែនឹង។

ក៖ ចឹងធ្វើតែស្រែទេណាម៉ាក់យាយ?

ខ៖ ចាំ!នឹងហើយ។

ក៖ ចុះម៉ាក់យាយធ្លាប់បង្កើតអាជីវកម្មលក់ដូរអីទេម៉ាក់យាយ?

ខ៖ អត់ទេនឹង។

ក៖ អត់ទេនម៉ាក់យាយ?

ខ៖ ចាំ!អត់ទេ។

ក៖ ចុះម៉ាក់យាយធ្លាប់ចិញ្ចឹមសត្វទេ ដូចជាមាន់ ទា ជ្រូក គោ ក្របីអីចឹង?

ខ៖ នៅលើវនឹងធ្លាប់ចិញ្ចឹមដែរនឹង។

ក៖ ចិញ្ចឹមច្រើនមែនម៉ាក់យាយ?

ខ៖ ចាំ!ចិញ្ចឹមតិចទេនឹង ចិញ្ចឹមតិចនឹងអត់មានច្រើនទេ។

ក៖ បាទចឹងម៉ាក់យាយធ្លាប់ទៅធ្វើស្រែចំការទេម៉ាក់យាយ?

ខ៖ ចាំ!ធ្លាប់ទៅចំការនឹងស្ទូងស្រូវស្រែ។

ក៖ អូ៎!បាទម៉ាក់យាយនឹង?

ខ៖ អត់សូវដាំអីទេនឹងទទួលគេនឹង។

ក៖ បាទចុះម៉ាក់យាយចូលចិត្តពិសារម្ហូបអីគេដែរម៉ាក់យាយ?

ខ៖ ធម្មតាទេខ្ញុំនឹងបើថាចូលចិត្តតែសម្លត្រួយល្ពៅននោងនឹង។

ក៖ អូ៎!នឹងសម្លដែរម៉ាក់យាយចូលចិត្តនឹង?

ខ៖ ចាំ!នឹងចូលចិត្ត។

ក៖
ចុះកាលពីក្មេងនឹងម៉ាក់យាយធ្លាប់លេងល្បែងប្រជាប្រិយ៍អីជាមួយមិត្តភក្តិម៉ាក់យាយទេ ដូចចោលឈូង បោះអង្គុញ ទាញព្រាត លាក់កន្សែង?

ខ៖ ចាំ!ធ្លាប់លេងចឹងដែរនឹង។

ក៖ ធ្លាប់លេងអីគេដែរម៉ាក់យាយ?

ខ៖ លេងបោសឈូង។

ក៖ បោសឈូងនឹងមីងចូលចិត្ត?

ខ៖ លេងលាក់កន្សែងអី។

ក៖ លេងចាប់កូនខ្លែងអីនឹងហោស?

ខ៖ ចាំ!នឹងហើយ។

ក៖ ចុះម៉ាក់យាយចេះច្រៀងទេម៉ាក់យាយ?

ខ៖ ខ្ញុំអត់ចេះទេ។

ក៖ ចុះម៉ាក់យាយចូលចិត្តស្តាប់បទចំរៀងអត់?

ខ៖ ពីដើមនឹងចេះតែស្តាប់ចឹងដែរប៉ុន្តែអត់ចេះទេ។

កៈ ប៉ុន្តែដល់ពេលឥឡូវនឹង?

ខៈ ឥឡូវនឹងចង់ស្តាប់តែលោកទេសទេ។

កៈ ម៉ាក់យាយចូលចិត្តស្តាប់ធិម ចុះអាយៃ យីកេអីម៉ាក់យាយចូលចិត្តស្តាប់ទេ?

ខៈ អត់សូវចេះទេអត់សូវចូលទេ។

កៈ អូ៎!បាទម៉ាក់យាយ?

ខៈ ចូលចិត្តស្តាប់តែធិមនឹងឥឡូវ ស្តាប់តែលោកទេសនឹងចំរៀងអីបិទអស់ហើយនឹង។

កៈ
ចុះម៉ាក់យាយគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់ម៉ាក់យាយចេះលេងឧបករណ៍ភ្លេង ដែរទេម៉ាក់យាយ?

ខៈ អត់ផងនឹង។

កៈ អត់ទេណាម៉ាក់យាយ?

ខៈ ចា៎!អត់មានទេ។

កៈ
ចុះផ្ទះរបស់ម៉ាក់យាយមានលក្ខណៈបែបណាដែរតាំងពីក្មេងរហូតមកដល់ឥឡូវនឹងហាសថាពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាស?

ខៈ ពីដើមនឹងផ្ទះតានើ
ឥឡូវនឹងចុះពីអាពតដែរមានផ្ទះធំដែរប៉ុន្តែឥឡូវនឹងកូនគេរកស៊ីខាតផ្ទះធំនឹង
លក់អោយគេអស់ហើយខ្ញុំក៏បានមកនៅផ្ទះតៀមវិញទៅ។

កៈ អូ៎!ប៉ុន្តែមកនៅនឹងមកនៅពីនាក់តា?

ខៈ ចា៎!នៅពីរនាក់តានឹង។

កៈ ចុះកូនៗៗនឹងគេទៅណាដែរទៅមីង?

ខៈ កូនៗៗនឹងគេបែកផ្ទះអស់ហើយនឹងនៅនេះមួយនៅលិចនឹងមួយ
ហើយនៅនោះនៅកំពង់សោមនោះ មួយនឹង។

កៈ អ៊ូ!បាទម៉ាក់យាយ?

ខៈ បែកផ្ទះអស់ហើយនឹងខ្ញុំនៅពីរនាក់យាយតានឹង។

កៈ ចុះផ្ទះរបស់ម៉ាក់យាយនៅនឹងនរណាគេជាអ្នកធ្វើដែរម៉ាក់យាយ?

ខៈ ផ្ទះនឹងគេជួយរហូតទេនេះផ្ទះស័ង្កសីនេះញាតិនៅក្នុងព្រះធិមជួយជុំវិញទិសនឹង។

កៈ បាទម៉ាក់យាយ?

ខៈ ចា៎!ជួយបានធ្វើដំបូលនឹងស័ង្កសីនឹងណាស់
ខ្ញុំធ្លាក់ខ្លួនក្រទៅហើយកូននឹងរកខាតហើយនឹងគេជួយ
រកជុំទិសទេនឹងតាំងពីរលោកបានផ្ទះស័ង្កសីនឹង។

កៈ បាទម៉ាក់យាយបាទ?

ខៈ ធ្លាក់ខ្លួនកំសត់នឹងជាជនទីរកត់ហើយនឹង។

កៈ បាទម៉ាក់យាយគិតថាជំនាញអីដែរម៉ាក់យាយចេះស្ទាត់ជំនាញដែរម៉ាក់យាយ?

ខៈ អត់ដែរមានចេះស្ទាត់អីទេនឹងល្ងង់ណាស់ខ្ញុំនឹង។

កៈ អ៊ូ!ចុះម៉ាក់យាយ?

ខៈ ល្ងង់មិនចេះរកអីទេឥឡូវនឹងដឹងតែទៅវត្តនឹង។

កៈ
ចុះម៉ាក់យាយគិតថាឪពុកម្តាយរបស់ម៉ាក់យាយធ្លាប់បង្រៀនពីជំនាញអីទៅម៉ាក់យាយទេ?

ខៈ គាត់ដូចខ្ញុំដឹងមកគាត់ធ្វើតែស្រែនឹង អត់មានជំនួញមានជំនាញអីទេ។

កៈ បាទម៉ាក់យាយ?

ខៈ ខ្ញុំដឹងធ្វើតែស្រែតែប៉ុណ្ណឹង
នឹងឡើងត្នោតឪពុកឡើងត្នោតនឹងមកគ្រួសារប្តីនឹងក៏ឡើងត្នោតដែរនឹង។

កៈ អ៊ូ!ចឹងហោសម៉ាក់យាយ?

ខៈ អ្នកស្រែសុទ្ធអត់មានចេះជំនាញអីទេនឹង។

កៈ
ចុះម៉ាក់យាយអាចប្រាប់ពីពេលលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះថាមានការពិបាក អីគេខ្លះ បានដែរទេម៉ាក់យាយ កាលពីក្មេងនឹងមានការលំបាកអីទៅ?

ខៈ កាលពីក្មេងនឹងមធ្យមទេកាលនៅជាមួយម៉ែឪនឹងមិនសូវពិបាកទេមកពិបាកខ្លាំងនឹង នៅជំនាន់ពលពតនឹង។

កៈ មានការពិបាកអីគេខ្លះដែរទៅម៉ាក់យាយ?

ខៈ ពិបាកជួននឹងអត់បាយហូបទេ។

កៈ ចុះម៉ាក់យាយពេលណុងគេជំលាសទៅណាដែរ?

ខៈ ជំលាសទៅមុនដំបូងនឹងឡើងទៅក្លូងអាយ
ចុះពីក្លូងអាយនឹងមកមកនៅត្រពាំងក្រឡឹងនឹងវិញនឹង។

កៈ បាទម៉ាក់យាយនឹង?

ខៈ ចុះមកត្រពាំងក្រឡឹងនឹងវិញហើយអត់មានបាយហូបចុះមកជីកដំឡូងនឹង។

កៈ អូ៎!បាទចុះគេអោយម៉ាក់យាយធ្វើអីគេដែរពេលណុង?

ខៈ អោយធ្វើស្រែនឹង។

កៈ ចុះពេលណុងម៉ាក់យាយមានអាយុប៉ុន្មានដែរហើយម៉ាក់យាយ?

ខៈ កាលណុងចុះមកពីអាពតនឹងដូចជាអាយុ30ឆ្នាំជាងហើយហី។

កៈ បាទម៉ាក់យាយ?

ខៈ ខ្ទង់ជាអាយុ40ឆ្នាំអីទេកាលណុង
ចុះមកពីជំនាន់អាពតនឹងវាសាមសិបជាងហើយនឹង។

កៈ វា39ឆ្នាំម៉ាក់យាយចុះពីជំនាន់ពលពតមកនឹងហាស?

ខៈ ចាំ!នឹងហើយចឹង។

កៈ ចឹងវាខ្ទង់40ឆ្នាំជាងហើយណម៉ាក់យាយ?

ខ៖ ហើយខ្ញុំនឹងខ្ទង់30ឆ្នាំជាងហើយនឹង។

ក៖ អូ៎!ចឹងមានន័យថាម៉ាក់យាយធំហើយណាម៉ាក់យាយ?

ខ៖ ខ្ញុំមានកូនមួយហើយនឹង
មានកូនមួយកូនពីរហើយនឹងនៅជំនាន់អាពតនឹងកូនពីរនាក់ហើយនឹង។

ក៖ ប៉ុន្តែកូនរបស់ម៉ាក់យាយនឹងគេយកទៅណាដែរម៉ាក់យាយ
គេអោយទៅជាមួយម្តាយឪពុករឺក៏គេ អោយយកទៅណាដែរម៉ាក់យាយ?

ខ៖
ទអោយនៅមណ្ឌលថ្មីនឹងបែកពីម៉ែឪនឹងបានកូនមួយនឹងគេអោយនៅបែកនឹងវារំក្រម៉ា
ណោះ នៅជើងភ្នំហោស។

ក៖ បាទម៉ាក់យាយបាទ?

ខ៖ ហើយម៉ែឪនឹងនៅភូមិនឹងហាស
ធ្វើស្រែចឹងទៅហើយកូននឹងជួយជញ្ជូនជីដាក់ស្រែចឹងដែរនឹង។

ក៖ បាទចុះសំរាប់ឪពុកម្តាយរបស់ម៉ាក់យាយនឹងគាត់នៅណាដែរម៉ាក់យាយ?

ខ៖ ឪពុករបស់ខ្ញុំនឹងគាត់ស្លាប់បាត់ហើយនឹង។

ក៖ នៅតែម្តាយទេ?

ខ៖ ចា៎!នៅតែម្តាយទេនឹង។

ក៖ ប៉ុន្តែម្តាយនៅណុងចាស់ហើយមែនទេម៉ាក់យាយ?

ខ៖ គាត់ចាស់ហើយគាត់នៅនឹងអាយុ68ឆ្នាំហើយ។

ក៖ ប៉ុន្តែកាលនៅជំនាន់ពលពតនឹងគាត់ចាស់នៅនៅតាហឹម៉ាក់យាយ?

ខ៖ គាត់ចាស់ហើយប៉ុន្តែចុះមកវិញនឹងបានជាគាត់ស្លាប់ទេនឹង។

ក៖ អូ៎!ប៉ុន្តែពេលណុងគេមិនអោយគាត់ធ្វើអីណាហឹម៉ាក់យាយ?

ខ៖ គេអោយគាត់ស្ទូងដកចឹងដែរនឹង។

កៈ អ៊ូ!ចុះកូនចៅរបស់ម៉ាក់យាយនឹងគេអោយធ្វើអីគេដែរម៉ាក់យាយ?

ខៈ
កូនមួយនឹងអាយុ7ឆ្នាំទៅ8ឆ្នាំហើយនឹងគេអោយដើរកាចកន្ទាំងខែតធ្វើជាជីនឹងបងគេនឹង។

កៈ អ៊ូ!បាទម៉ាក់យាយនឹង ចុះប្អូនៗវិញម៉ាក់យាយ?

ខៈ ប្អូនក៏ធ្វើជីចឹងដែរនឹង។

កៈ បាទម៉ាក់យាយ
រហូតមកដល់ឥឡូវនឹងម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់ជួបការលំបាកអីគេដែរទៅ?

ខៈ លំបាកចុះពីអាពតនឹងមកលំបាកទៀតនឹង។

កៈ មានការលំបាកអីគេខ្លះដែរម៉ាក់យាយ?

ខៈ ពិបាករកមិនទាន់បានហូបបង្កើតផលមិនទាន់កើតនឹង។

កៈ ពេលណុងយើងមិនទាន់មានចាយលុយចាយអីទេណាម៉ាក់យាយ?

ខៈ ចា៎!អត់ទាន់ចាយលុយនឹងពិបាកមួយគ្រានឹងទៀត។

កៈ ពិបាកខ្លាំងតែម្តងហោសម៉ាក់យាយ?

ខៈ ពិបាកជំនាន់ពលពតនឹងក៏ពិបាកនឹងលំបាកចុះមកនឹង។

កៈ ពេលណុងលឺថាគេអោយចាប់ដីចាប់អីនៅមែនទេម៉ាក់យាយ?

ខៈ ចា៎!មកដល់ចាប់ដីចែកមកធ្វើស្រែទៅនឹងបង្កើនផលហូប
ហើយហូបមិនបានគ្រប់គ្រាន់ទេនឹង ដីកំលាំងធំនឹងបានតែ9អាទេ។

កៈ បាទម៉ាក់យាយចឹង?

ខៈ ហូបមិនគ្រប់មិនគ្រាន់ទេសព្វថ្ងៃនឹងអស់ទៅទៀតនឹង។

កៈ
អ៊ូ!បាទចឹងម៉ាក់យាយគិតថាឆ្លងកាត់ការលំបាកដែរម៉ាក់យាយរៀបរាបមិញនឹងដោយរបៀ
បណាដែរ ម៉ាក់យាយ?

ខ៖ ពិបាកដូចថាយើងមិនទាន់បានធ្វើអត់ទាន់បង្កើនផលហូបនឹងស្រុករត់ចឹងនោះ។

ក៖ បាទម៉ាក់បាទនឹង?

ខ៖ ចាំ!ពិបាកចឹងនោះហើយខ្លាំចុំមកទៀតនឹងទំរាំតែបង្កើតផលនឹងបានវាយូរ។

ក៖ បាទចុះពេលណាដែរម៉ាក់យាយគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់ម៉ាក់យាយដែរ?

ខ៖ អត់មានពេលដែរសប្បាយទេ។

ក៖ ម៉េចចឹងម៉ាក់យាយ?

ខ៖ បើអត់ពិបាកតែរហូតនឹងខ្ញុំកំសត់ជាងគេនឹង។

ក៖ ម៉ាក់យាយពិបាករហូតតែម្តងនឹង?

ខ៖ ចាំ!នឹងហើយនឹង។

ក៖ ពិបាកខ្លាំងជាងគេនឹងនៅជំនាន់ពលពតមែនទេម៉ាក់យាយ?

ខ៖ ចាំ!នៅជំនាន់អាពតនឹង។

ក៖ គេធ្វើបាបយើងខ្លាំងហោសម៉ាក់យាយ?

ខ៖ ចាំ!ចុះពីណុងមកពិបាកបង្កើនផលមកបានតិចដែរទេ។

ក៖ អូ៎!បាទចឹងម៉ាក់យាយ?

ខ៖ ពិបាកជាងគេនឹងនៅជំនាន់ពលពតនឹង។

ក៖ ចុះបើសិនជាគេចង់អោយម៉ាក់យាយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗហាស តើម៉ាក់យាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរម៉ាក់យាយ?

ខ៖ ខ្ញុំមិនដឹងថាផ្តែផ្តាំថាម៉េចទេនឹង មានតែយើងដឹងរឿងចឹងមានតែដឹងថាជំនាន់ពលពតលំបាកចឹងមាន តែប្រាប់ប៉ុណ្ណឹង។

ក៖ អូ៎!បាទម៉ាក់យាយ?

ខ៖ ចា៎!មានតែប៉ុណ្ណឹងទេ។

ក៖
ចុះបើសិនជាចង់អោយគាត់ជៀសវៀងវិញតើម៉ាក់យាយចង់អោយពួកគាត់ជៀសវៀងពីអីគេដែរ ម៉ាក់យាយនឹង?

ខ៖ ជៀសវៀងយ៉ាងម៉េចដែរ?

ក៖
ជៀសវៀងអំពីអំពើមួយដែរមិនល្អដូចថាលក្ខណះថាជក់គ្រឿងញៀនអីចឹងហាសម៉ាក់យាយ?

ខ៖ អត់កូនចៅរបស់ខ្ញុំនឹងវាមិនអីទេ មិនដែរផឹកស៊ីអីទេវានៅតូចៗៗនឹង។

ក៖ អូ៎!បាទម៉ាក់យាយ
ចុះម៉ាក់យាយមានធ្លាប់មានក្ដីស្រម៉ៃថាពេលដែរធំឡើងនឹងម៉ាក់យាយចង់ធ្វើអីទេ?

ខ៖ មានតែចង់ធ្វើអីទេមានតែទៅវត្ត។

ក៖ អូ៎!ទៅវត្តហោសម៉ាក់យាយ?

ខ៖ ទៅវត្តថ្ងៃសិល្ប៍ ភ្ជុំទៅវត្ត ចូលឆ្នាំទៅវត្តមានតែប៉ុណ្ណឹងទេឥឡូវនឹង។

ក៖ បាទចឹងមានអីចង់ផ្ដែផ្ដាំទៅពួកគាត់ទៀតទេម៉ាក់យាយ?

ខ៖ អត់មានអីទៀតទេ។

ក៖
បាទចឹងជាចុងក្រោយនឹងខ្ញុំអរគុណច្រើនម៉ាក់យាយដែរបានអោយខ្ញុំពិភាក្សាដែរទាក់ទងពីប្រវត្តិ របស់ម៉ាក់យាយ ហើយប្រវត្តរបស់ម៉ាក់យាយដែរខ្ញុំបានសំភាសន៍នឹង ខ្ញុំនឹងដាក់ការសំភាសន៍មួយនឹង ទៅក្នុងវេបសាយរបស់សាលា ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗអោយពួកគាត់បានស្គាល់ពីប្រវត្តិ របស់ដូនតាចឹងហាសម៉ាក់យាយណា?

ខ៖ ចា៎!!!នឹងហើយចឹង។

ក៖ បាទអរគុណច្រើនម៉ាក់យាយ៕៕៕